# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋឈីលី
# ស្ដីពី
# ការលើកលែងទិដ្ឋាការសំរាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋឈីលី អំណឹះតទៅហៅថា "ភាគី"។

ដោយមានបំណងពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តការរវាងប្រទេសទាំងពីរ។

ដោយទទួលស្គាល់នូវតំរូវការដើម្បីសំរួលការធ្វើដំណើរចេញ-ចូលក្នុងទឹកដីនៃប្រទេសនីមួយៗរបស់ពលរដ្ឋនៃប្រទេសទាំងពីរ ដែលកាន់លិខិតឆ្លងដែនការទូត និងផ្លូវការដែលមានសុពលភាព។

បានព្រមព្រៀងដូចតទៅៈ

## មាត្រា ១

ពលរដ្ឋនៃភាគីនីមួយៗដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការមានសុពលភាព និងពុំមាននិវេសនដ្ឋាននៅក្នុងទឹកដីនៃភាគីម្ខាងទៀត ត្រូវលើកលែងទិដ្ឋាការ ចូល ឆ្លងកាត់ ស្នាក់នៅ និងចេញពីទឹកដី នៃភាគីនីមួយៗ ក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃចាប់ពីថ្ងៃចូល។

## មាត្រា ២

ការពន្យារយៈពេលស្នាក់នៅដូចមានចែងក្នុងមាត្រា១ ជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ តាមការស្នើសុំជាលាយលក្ខអក្សរនៃបេសកកម្មការទូត ឬកុងស៊ុលនៃរដ្ឋដាក់ទូត។

ក្នុងករណីគ្មានបេសកកម្មការទូត ឬកុងស៊ុលនៃភាគីទាំងពីរ អ្នកកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការមានសុពលភាព ត្រូវស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ច នៃក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ។

## មាត្រា ៣

ពលរដ្ឋនៃភាគីនីមួយៗដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការមានសុពលភាព ដែលជាសមាជិកនៃបេសកកម្មការទូត កុងស៊ុល ឬតំណាងផ្លូវការក្នុងអង្គការអន្តរជាតិ នៅក្នុងទឹកដីនៃភាគីនីមួយៗ ព្រមទាំងសមាជិកគ្រួសារនៅក្នុងបន្ទុកដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការមានសុពលភាព ត្រូវលើកលែងទិដ្ឋាការ ចូល ឆ្លងកាត់ ស្នាក់នៅ និងចេញពីទឹកដីនៃភាគីនីមួយៗក្នុងកំឡុងពេលបំពេញការងាររបស់ពួកគេ ប្រសិនបើ

ពួកគេបានបំពេញបែបបទស្នាក់នៅរបស់ភាគីម្ខាងទៀត ក្នុងកំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីការមកដល់ក្នុងទឹកដីនៃភាគីនីមួយៗ។

## មាត្រា ៤

ពលរដ្ឋដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ អាចចូល ឆ្លងកាត់ និងចេញពីទឹកដីនៃភាគីនីមួយៗ តាមច្រកទ្វារព្រំដែនអន្តរជាតិ។

## មាត្រា ៥

ពលរដ្ឋនៃភាគីនីមួយៗដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការមានសុពលភាព ត្រូវគោរពច្បាប់និងបទបញ្ញត្តិជាធរមាននៃភាគីម្ខាងទៀត ក្នុងកំឡុងពេលស្នាក់នៅក្នុងទឹកដីនៃភាគីនោះ។

## មាត្រា ៦

ភាគីនីមួយៗរក្សាសិទ្ធិបដិសេធដោយឈរលើមូលដ្ឋានធន្ទានុសិទ្ធិ ការចូលទៅក្នុងទឹកដីរបស់ខ្លួន នូវបុគ្គលដែលចាត់ទុកថាជា "បុគ្គលមិនស្វាគមន៍" ។

## មាត្រា ៧

១. ភាគីទាំងពីរត្រូវធ្វើការផ្លាស់ប្តូរ តាមផ្លូវការទូតនូវគំរូលិខិតឆ្លងដែនដូចមានបញ្ជាក់នៅក្នុងមាត្រា១ នៃកិច្ចព្រមព្រៀងនេះ យ៉ាងយូរបំផុត ៣០ថ្ងៃ មុនពេលចូលជាធរមាននៃកិច្ចព្រមព្រៀង។

២. ប្រសិនបើភាគីណាមួយផ្លាស់ប្តូរលិខិតឆ្លងដែនថ្មី ឬដាក់ឲ្យប្រើប្រាស់នូវលិខិតឆ្លងដែនថ្មី បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ត្រូវជូនព័ត៌មានទៅភាគីម្ខាងទៀតនូវគំរូលិខិតឆ្លងដែនថ្មីនោះ តាមផ្លូវការទូតយ៉ាងយូរ ៣០ថ្ងៃ មុនការដាក់ឲ្យប្រើប្រាស់។

## មាត្រា ៨

ភាគីនីមួយៗអាចផ្អាក ឬ ពន្យាការអនុវត្តកិច្ចព្រមព្រៀងនេះ។ ការផ្អាក ឬពន្យានេះ ត្រូវជូនព័ត៌មានទៅវិញទៅមកជាលាយលក្ខអក្សរតាមផ្លូវការទូតដោយបញ្ជាក់មូលហេតុច្បាស់លាស់។ ការផ្អាក ឬពន្យានេះ ត្រូវអនុវត្តភ្លាមបន្ទាប់ពីការជូនព័ត៌មានជាលាយលក្ខអក្សរ។

## មាត្រា ៩

រាល់វិវាទដែលកើតចេញពីការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយជាមិត្តភាពតាមរយៈការពិគ្រោះយោបល់ និងការចរចាររវាងភាគីទាំងពីរ។

## មាត្រា ១០

១.កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានរយៈពេល ៦០ថ្ងៃ បន្ទាប់ពីការទទួលបានការជូនព័ត៌មានជាលាយលក្ខអក្សរចុងក្រោយតាមផ្លូវការទូតអំពីការបំពេញចប់សព្វគ្រប់នូវនិតិវិធីផ្ទៃក្នុង ដើម្បីឲ្យកិច្ចព្រមព្រៀង នេះចូលជាធរមាន។

២.កិច្ចព្រមព្រៀងនេះអាចធ្វើវិសោធនកម្មដោយមានការព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីទាំងពីរ និងជូនព័ត៌មានគ្នាតាមផ្លូវការទូត។ ការធ្វើវិសោធនកម្មនេះ ត្រូវចូលជាធរមាន ស្របតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ។

៣.កិច្ចព្រមព្រៀងនេះស្ថិតនៅជាធរមាន ប្រសិនបើពុំមានភាគីណាមួយស្នើសុំលុបចោល តាមផ្លូវការទូត។ ការប្រកាសលុបកិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពរយៈពេល ៩០ថ្ងៃ បន្ទាប់ពីទទួលបានការជូនព័ត៌មានជាលាយលក្ខអក្សរ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ជាពីរច្បាប់ដើម ជាភាសាខ្មែរ អេស្ប៉ាញ និងអង់គ្លេស ដែលអត្ថបទនីមួយៗមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកជាឯកសាគោល។

ជ.រដ្ឋាភិបាល
នៃព្រះរាជាណាចក្រកម្ពុជា

ឯកឧត្តម អ៊ុច បូរិទ្ធ
រដ្ឋលេខាធិការ
ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

ជ.រដ្ឋាភិបាល
នៃសាធារណរដ្ឋឈីលី

អាល់ហ្វ្រេដូ ឡាបេ វីឡា
ឯកអគ្គរដ្ឋទូត
អគ្គនាយកទទួលបន្ទុកនយោបាយការបរទេស
ក្រសួងការបរទេស